## បត្យាប័ន (Extradition)

បត្យាប័ន ជាមធ្យោបាយសហការរវាងរដ្ឋនិងរដ្ឋ ដើម្បីបង្ក្រាបបទល្មើស។ បត្យាប័ន ខុសពី ការប្រគល់ខ្លួន (surrender) ដែលសំដៅលើការបញ្ជូនជនណាមួយទៅតុលាការអន្តរជាតិ។ កិច្ចព្រមព្រៀងពហុភាគី ឬ ទ្វេភាគី បានចែងអំពីបត្យាប័ន ដោយក្នុងនោះ បានបង្កើតជាកាតព្វកិច្ចធ្វើបត្យាប័ន ចំងដល់រដ្ឋជាភាគី។ ទោះបីជាយ៉ាងនេះក្តី កាតព្វកិច្ចនោះ មិនដាច់ខាតទេ (absolute obligation) ដោយសារកត្តាមួយចំនួន មានចែងក្នុងសន្ធិសញ្ញា ឬច្បាប់ជាតិ។

កិច្ចព្រមព្រៀងពហុភាគីខ្លះ បានបង្កើតនូវកាតព្វកិច្ច បញ្ជូន ឬកាត់សេចក្តី (*aut dedere aut judicare*) ក្នុងន័យថារដ្ឋ អាចធ្វើការវិនិច្ឆ័យសេចក្តី ប្រសិនបើមិនធ្វើបត្យាប័ន។

ក្រោមច្បាប់ជាតិ បត្យាប័ន មិនអាចធ្វើទៅរួចប្រសិនបើ មិនបានបំពេញបំពេញមូលដ្ឋានមួយចំនួនដូចជា dual criminality (បទល្មើសត្រូវមានចែងក្នុងច្បាប់ប្រទេសទាំងពីរ)។ មូលដ្ឋានខ្លះ មានចរិតដាច់ខាត (mandatory ground) ក្នុងន័យថា ប្រសិនបើមិនបំពេញទេ មិនអនុញ្ញាតឲ្យធ្វើបត្យាប័នពីព្រោះខុសនឹងច្បាប់ជាតិ។ នោះគឺករណី រយៈពេលចោទប្រកាន់បានកន្លងហួសទៅហើយ (expiration of statute of limitation)។ បន្ថែមពីលើនេះ ប្រទេសខ្លះ មិនអនុញ្ញាតឲ្យធ្វើបត្យាប័នជនជាតិខ្លួនឡើយ។

ចំពោះបត្យាប័ន ដើម្បីយកជនណាមួយទៅកាត់ទោស ប្រទេសខ្លះទាមទារនូវភស្តុតាងច្បាស់ក្រឡែតជាបឋម (*prima facie* evidence) ឬ កម្រិតភស្តុតាង probable cause (សហរដ្ឋអាមេរិក) ឬ មូលដ្ឋានសមស្រប ដើម្បីជឿថា បុគ្គលនោះបានប្រព្រឹត្តបទល្មើស (reasonable basis to believe that the person committed the offense)។

ក្នុងអំឡុងដំណើរការបត្យាប័ន រដ្ឋអាចស្នើសុំឲ្យមានការឃុំខ្លួនបណ្តោះអាសន្ន។ ក្នុងករណី បញ្ជូនទៅតាមរយៈបត្យាប័ន នឹងនាំឲ្យមានការកាត់ទោសប្រហារជីវិត រដ្ឋត្រូវសុំការធានាពីរដ្ឋ ថានឹងមិនប្រហារជីវិតទេ ក្រោយពេលទទួលជននោះ (*Ng v. Canada,* Human Rights Committee, Communication No. 469/1991) (Antonio, the Oxford Companion to the International Criminal Justice, Extradition, 2009, pp. 321-322)។

ដោយសារបត្យាប័ន មានភាពស្មុគ្រស្មាញ ទាំងនីតិវិធី និងចំណាយពេលច្រើន សហគមអឺរ៉ុបបានបង្កើតយន្តការ European Arrest Warrant អនុវត្តក្នុងចំណោមប្រទេសសមាជិក។

**ខ្លឹមសារបន្ថែម៖** បត្យាប័ន ខុសគ្នាផងដែរនឹងពាក្យ បណ្តេញចេញ (expulsion) ដែលអនុវត្តសម្រាប់ដេញជនបរទេស ដែលរស់នៅខុសច្បាប់ក្នុងប្រទេស។